**អត្ថបទស្តីពីភាពជោគជ័យនៃគម្រោង**

# ទំនប់ភ្នំមាសត្រូវបានស្តាររួច និងជាក្តីសង្ឃឹមរបស់អ្នកភូមិ

## កង្វះទឹកសម្រាប់ស្រោចស្រពស្រែចម្ការគឺជាបញ្ហាចម្បងដែលរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងភូមិភ្នំមាស ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។

ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ (ក្រុងក្រចេះ)

ប្រជាពលរដ្ឋសរុបក្នុងឃុំថ្មី មានចំនួន២,០៨១ គ្រួសារ (ស្ត្រី ៥,៣៩៩នាក់)ដោយភាគច្រើនរស់នៅប្រកបរបរកសិកម្ម រួមមានធ្វើស្រែចម្ការ ដាំដំណាំបន្លែ ចិញ្ចឹមសត្វ ក៏ដូចជាពឹងអាស្រ័យមួយផ្នែកលើអនុផលព្រៃឈើផងដែរ។ ដោយសារតែកត្តាប្រែប្រួលអាកាសធាតុទើបធ្វើឱ្យប្រជាពលរដ្ឋដែលរស់នៅទីនោះជួបប្រទះនូវកង្វះទឹកស្រោចស្រព និងជាហេតុធ្វើឱ្យជីវភាពរបស់ពួកគាត់ត្រូវជួបការលំបាក។ ស្របតាមផែនការយុទ្ធសាស្ត្ររបស់អង្គការដើម្បីជីវភាព និងព្រៃឈើ (FLO) បានដាក់ចេញនូវសកម្មភាពជាច្រើនដូចជា ស្តារទំនប់ទឹក ស្តារអណ្តូងទឹក ស្រះទឹក បង្កើតក្រុមសន្សំ និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម។



លោក មុំ ខាំ ប្រធានក្រុមប្រឹក្សាឃុំថ្មី ដែលបានបង្ហាញពីលទ្ធផលល្អនៃការអនុវត្តគម្រោងរបស់អង្គការដើម្បីជីវភាព និងព្រៃឈើ ដែលបានជួសជុល និងស្តារទំនប់ទឹកជូនប្រជាពលរដ្ឋអ្នកភូមិភ្នំមាស។

ដោយឡែកសម្រាប់ការស្តារទំនប់ភ្នំមាសនេះ លោកមុំ ខាំ ដែលជាប្រធានក្រុមប្រឹក្សាឃុំថ្មី បានឱ្យដឹងថា *"ដើមឡើយ ប្រជាពលរដ្ឋខ្វះទឹកសម្រាប់បរិភោគ និងស្រោចស្រពដំណាំផ្សេងៗ រីឯសត្វពាហនៈក៏លំបាកក្នុងការស្វែងរកទឹកផឹក ហើយមានការបាត់គោក្របីផងដែរ។ ប៉ុន្តែក្រោយមកនាឆ្នាំ២០១២ អង្គការ FLO បានចំណាយថវិកាចំនួន ១,១៥០០ ដុល្លារសហរដ្ឋអាមេរិក ដើម្បីជួសជុលទំនប់ទឹកនេះឱ្យល្អប្រសើរឡើងវិញ។* លោក មុំ ខាំ ក៏បានបន្តទៀតថា *"ទំបន់ទឹកនេះមិនត្រឹមតែផ្តល់ទឹកសម្រាប់ប្រជាពលរដ្ឋបរិភោគប៉ុណ្ណោះទេ ថែមទាំងអាចឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារតាមរយៈការដាំដុះស្រែចម្ការ និងទទួលបានផលដំណាំខ្ពស់ ហើយទំនប់នេះសម្បូរទៅដោយជីវចម្រុះ ត្រី និងសត្វស្លាបផងដែរ។"*




ទំបន់ភ្នំមាស ដែលត្រូវបានស្តារ និងជួលជុល ដោយគម្រោងអង្គការ FLO ដើម្បីដោះស្រាយចំពោះកង្វះទឹកសម្រាប់បរិភោគ និងស្រោចស្រពស្រែចម្កា ដំណាំបន្លែ និងសត្វពាហៈនៈ។

ចំណែកលោកតា ម៉េត ផយ អាយុ៨០ឆ្នាំដែលជាសមាជិកគណៈកម្មការគ្រប់គ្រងទំនប់ទឹកភ្នំមាស និងជាអ្នករស់នៅក្បែរទំនប់នោះបានបញ្ជាក់ថា *"បច្ចុប្បន្ន ទំបន់នេះអាចស្រោចស្រពដំណាំស្រូវ និងដំណាំបន្លែផ្សេងៗក្នុងកូនរដូវប្រាំង ប៉ុន្តែមិនអាចគ្រប់គ្រាន់ពេញលេញក្នុងមួយរដូវប្រាំងនោះទេ ដោយសារទំនប់ទឹកនេះស្តុកទឹកបានតិចតួចពេក។"* លោកតាផយ បន្ថែមទៀតថា *"នៅពេលមានទឹកគ្រប់គ្រាន់ដូច្នេះ យើងអាចដាំស្រូវ និងដំណាំផ្សេងៗដូចជាពោត ត្រសក់ ស្ពៃ ននោង ល្ពៅ ត្រកួន ដើម្បីទុកបរិភោគក្នុងគ្រួសារផង និងលក់ដូរនៅតាមទីផ្សារផង រីឯគោក្របីរបស់អ្នកភូមិ ក៏មិនបាត់បង់ទៀតដែរ។"*

**ទំនប់ភ្នំមាស៖**

-ប្រវែង ២៥០ម៉ែត្រ -កម្ពស់ ៣ម៉ែត្រ -ខ្នងទំនប់ ៥ម៉ែត្រ -ជម្រៅជើងទេ ៩ម៉ែត្រ

**Forest and Livelihood Organization (FLO)**
House 660, Street 2, Tropaing Prieng village, Sangkat Kratie, Kratie town, Kratie Province.
E-mail: info@cambodia.org Tel: (+855) 72 5000 135 Website: www.flocambodia.org